**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.........................................................

# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ២០២៥
# រវាង ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលឡាវ

ថ្ងៃសុក្រ ១៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥

Sabaidee!

**សូមគោរព៖**

- **លោកជំទាវ** Bounkham Vorachit **ទេសាភិបាលធនាគារកណ្ដាលឡាវ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្ស និងសូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះលោកជំទាវទេសាភិបាល និងគណៈប្រតិភូធនាគារកណ្ដាលឡាវ ដែលបានចំណាយពេលដ៏មមាញឹកអញ្ជើញចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំរវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្ដាលឡាវនៅរាជធានីភ្នំពេញ។

ជាបឋម ខ្ញុំសូមណែនាំសមាសភាពគណៈប្រតិភូធនាគារជាតិនៃកម្ពុជា ដូចតទៅ៖

- ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង
- ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ទេសាភិបាលរង
- លោកជំទាវ ស្រី ស៊ីយុត ឧបការីទេសាភិបាល និងជាអគ្គពិនិត្យ
- ឯកឧត្តម គីមទី កោមលី ឧបការីទេសាភិបាល និងជាអគ្គនាយកប្រតិបត្តិការ
- ឯកឧត្តម គិត សុវណ្ណារិទ្ធ ឧបការីទេសាភិបាល និងជាអគ្គនាយកត្រួតពិនិត្យ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- លោក ឃូ វុណ្ណី ឧបការីទេសាភិបាល និងជាអគ្គនាយក គោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ
- លោក អ៊ិត អេរ៉ូ អគ្គនាយករងគោលនយោបាយនិងសហប្រតិបត្តិការ អន្តរជាតិ និងជាប្រធាននាយកដ្ឋានស្ថិតិ
- លោក អ៊ុក សារ៉ាត អគ្គនាយករងប្រតិបត្តិការ និងជាប្រធាននាយកដ្ឋាន ប្រព័ន្ធទូទាត់សងប្រាក់
- លោក ឡុង វិបុណ្យឫទ្ធ អគ្គនាយករងប្រតិបត្តិការ
- លោកស្រី ស៊ុំ សុទ្ធី ប្រធាននាយកដ្ឋានគ្រប់គ្រងទុនបម្រុង
- លោកស្រី ជា សុផល នាយិកាវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ និងជានាយិការងខុទ្ទកាល័យ
- លោកស្រី ងិន គន្ធា ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង
- លោកស្រី ប៉ុន ដាលីន ប្រធាននាយកដ្ឋានបរិយាបន្នហិរញ្ញវត្ថុ។

ឆ្លៀតក្នុងឱកាសនេះ និងជាថ្មីម្តងទៀត ខ្ញុំសូមចូលរួមអបអរសាទរជូនចំពោះ លោកជំទាវ Bounkham Vorachit ដែលត្រូវបានតែងតាំងជា ទេសាភិបាល ធនាគារកណ្តាល ឡាវ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏វាងវៃរបស់លោកជំទាវ ធនាគារ កណ្តាលឡាវនឹងបន្តអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័ស ហើយកិច្ចសហប្រតិបត្តិការ ទ្វេភាគីរវាងស្ថាប័នទាំងពីរនឹងត្រូវបានពង្រឹងនិងពង្រីកថែមមួយកម្រិតទៀត។ កិច្ចប្រជុំ ទ្វេភាគីរបស់យើងនាថ្ងៃនេះ បានបង្ហាញជាសក្ខីភាពយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តក្នុង ការពង្រឹងកិច្ចសហប្រតិបត្តិការជាមិត្តភាពយូរអង្វែង។

អស់រយៈពេលជាច្រើនឆ្នាំមកនេះ ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលឡាវ រក្សាបានទំនាក់ទំនងជិតស្និទ្ធ ប្រកបដោយលក្ខណៈស្ថាបនា និងឈរលើមូលដ្ឋាននៃ ទំនុកចិត្តទៅវិញទៅមក។ ក្នុងន័យនេះ ខ្ញុំពិតជាមានក្តីសោមនស្សរីករាយដែលបាន

ឃើញថា កិច្ចសហប្រតិបត្តិការនេះត្រូវបានពង្រីកវិសាលភាពលើសពីកម្រិតថ្នាក់ដឹកនាំ រហូតដល់ការសហការយ៉ាងសកម្មនិងប្រកបដោយផ្លែផ្កា រវាងមន្ត្រីបច្ចេកទេសរបស់យើង។

ជាក់ស្តែង ការដាក់ឱ្យប្រើប្រាស់យ៉ាងជោគជ័យនៃការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែន តាមរយៈឃ្យូអរកូត គឺជាភស្តុតាងនៃកិច្ចសហប្រតិបត្តិការដ៏ល្អនេះ។ ការដាក់ឱ្យដំណើរការដំណាក់កាលទី១ កម្ពុជាស្តេនឃ្យូអរកូតឡាវ កាលពីឆ្នាំ២០២៣ កន្លងមក បានបង្កើតបរិយាកាសអំណោយផលសម្រាប់ប្រជាជនកម្ពុជាធ្វើការទូទាត់ទំនិញនិងសេវាក្នុងប្រទេសឡាវ។ ថ្ងៃនេះ ខ្ញុំពិតជាមានមោទនភាព ដែលយើងនឹងដាក់ឱ្យដំណើរការដំណាក់កាលទី២ ឡាវស្តេនខេអេចឃ្យូអរកូតកម្ពុជា ដើម្បីអនុវត្តគម្រោងនៃការតភ្ជាប់នេះឱ្យពេញលេញ។ គំនិតផ្តួចផ្តើមនេះ នឹងបង្កភាពងាយស្រួលដល់ទេសចរ អាជីវករ និងពាណិជ្ជករក្នុងការធ្វើប្រតិបត្តិការសម្រាប់ការធ្វើដំណើរនិងទិញទំនិញឆ្លងដែន។ ថ្វីត្បិត គម្រោងនៃការតភ្ជាប់នេះជាការងារបច្ចេកទេស ប៉ុន្តែការតភ្ជាប់នេះពិតជាមានអត្ថន័យ និងមានឥទ្ធិពលជាវិជ្ជមានលើប្រជាជនគ្រប់រូប ដោយសារការតភ្ជាប់ប្រព័ន្ធទូទាត់បានកាត់បន្ថយពេលវេលា និងថ្លៃដើម ជាពិសេសបានផ្សារភ្ជាប់សេដ្ឋកិច្ចនិងប្រជាជននៃប្រទេសទាំងពីរ។

ដូចគ្នានេះដែរ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការផ្លាស់ប្តូរចំណេះដឹងនិងបទពិសោធរវាងមន្ត្រីនៃធនាគារកណ្តាលទាំងពីរតាមរយៈការធ្វើទស្សនកិច្ចសិក្សា កិច្ចពិភាក្សាបច្ចេកទេស និងការទំនាក់ទំនងគ្នាជាប់ជាប្រចាំ ដែលបានអនុញ្ញាតឱ្យមន្ត្រីជំនាញទាំងសងខាងបានរៀនសូត្រនិងដកស្រង់បទពិសោធទៅវិញទៅមកទៅលើផ្នែកនយោបាយរូបិយវត្ថុ ការត្រួតពិនិត្យធនាគារ ប្រព័ន្ធទូទាត់ និងការគ្រប់គ្រងទុនបម្រុង ជាដើម។ ការផ្លាស់ប្តូរបទពិសោធទៅវិញទៅមកនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងសមត្ថភាពស្ថាប័ននិងការត្រៀមខ្លួនដើម្បីដោះស្រាយបញ្ហាប្រឈមដែលអាចកើតមានឡើងជាយថាហេតុក្នុងបរិការណ៍នៃការកើនឡើងភាពប្រទាក់ក្រឡានៃពិភពលោក។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

កិច្ចប្រជុំនាព្រឹកនេះ នឹងផ្តល់ឱកាសឱ្យយើងផ្លាស់ប្តូរទស្សនៈលើស្ថានភាពម៉ាក្រូ-សេដ្ឋកិច្ច វឌ្ឍនភាពក្នុងវិស័យធនាគារ ការគ្រប់គ្រងទុនបម្រុង និងប្រព័ន្ធទូទាត់ ជាដើម។ ខ្ញុំសង្ឃឹមថា កិច្ចពិភាក្សា និងការផ្លាស់ប្តូរមតិរបស់យើងនាពេលបន្តិចទៀតនេះ នឹងជួយដល់ការកំណត់អាទិភាពនៃការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឡាវ ថែមទៀត។

ខ្ញុំជឿជាក់ថា កិច្ចពិភាក្សារបស់យើងនាថ្ងៃនេះនឹងមានលក្ខណៈស្ថាបនានិងផ្តល់ជាទស្សនៈអនាគត ដែលនឹងពង្រឹងភាពជាដៃគូស៊ីជម្រៅរវាងធនាគារកណ្តាលទាំងពីរ។

ជាថ្មីម្តងទៀត ខ្ញុំសូមស្វាគមន៍ លោកជំទាវ ទេសាភិបាល និងគណៈប្រតិភូធនាគារកណ្តាលឡាវមកកាន់រាជធានីភ្នំពេញ និងសូមឱ្យកិច្ចប្រជុំទ្វេភាគីរបស់យើងប្រព្រឹត្តទៅដោយភាតរភាពនិងជោគជ័យ។

**សូមអរគុណ!**